**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

## សារលិខិតផ្ញើជូនចំពោះ កុលបុត្រ កុលធីតា កម្ពុជា ពីលោក យ៉ាសហ៍ ឃ្លាយ
## តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ១០ ធ្នូ ២០០៥

ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមផ្ញើសារលិខិតនេះ ជូនចំពោះកុមារ និងយុវជនកម្ពុជាទាំងអស់ ក្នុងឱកាសទិវាសិទ្ធិមនុស្ស ដែលនេះជាលើកដំបូងហើយចាប់តាំងពីខ្ញុំបានទទួលការតែងតាំង ដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងតួនាទីជាតំណាងពិសេសរបស់លោក ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ។

ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ជនគ្រប់រូបបានដឹងថា ការឈឺចាប់របស់ប្រជាជន គឺបណ្តាលមកពីអំពើរំលោភដ៏ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ។ ពួកគេបានប្តេជ្ញាចិត្តថា នឹងមិនបណ្តោយឱ្យមានការបដិសេធសិទ្ធិរបស់ខ្លួនជាថ្មីទៀតឡើយ ។ ប្រជាពលរដ្ឋកម្ពុជា បានដាក់ការការពារសិទ្ធិមនុស្សយ៉ាងខ្ពស់នៅក្នុងរដ្ឋធម្មនុញ្ញថ្មីរបស់ខ្លួន ។ សហគមន៍អន្តរជាតិបានសន្យាជួយប្រទេសកម្ពុជាក្នុងការអភិវឌ្ឍន៍ និងការគោរពសិទ្ធិមនុស្ស ។

បច្ចុប្បន្ននេះ ឥរិយាបថចំពោះសិទ្ធិមនុស្សបែរជាមានការបែងចែកយ៉ាងខ្លាំង ដោយអ្នកខ្លះគិតថា អ្នកការពារសិទ្ធិមនុស្ស គឺជាអ្នកបង្កបញ្ហា និង ឧបសគ្គដល់ការអភិវឌ្ឍន៍ ។ ការពោលអះអាងបែបនេះ គឺជាការភាន់ច្រឡំអំពីអត្ថន័យពិតប្រាកដនៃសិទ្ធិមនុស្ស ។ ដូច្នេះ តើអ្វីទៅជាសិទ្ធិមនុស្សពិតប្រាកដនោះ? មនោគតិ នៃសិទ្ធិមនុស្សបានកើតមានឡើង នៅក្នុងបរិបទសង្គម និង ប្រវត្តិសាស្ត្រដោយឡែកមួយ គឺនៅក្នុងខណៈដែលមានការតស៊ូយ៉ាងច្រើន ប្រឆាំងនឹងការសង្កត់សង្កិនដោយមនុស្សជាច្រើននៅលើពិភពលោកទាំងមូល សិទ្ធិបានក្លាយទៅជាកត្តាគន្លឹះ ក្នុងការបង្កើតនូវសង្គមមួយ ដែលផ្តល់ឱ្យជនគ្រប់រូបនូវឱកាសពិតប្រាកដ ដើម្បីមានជីវិតរស់នៅ ប្រកបដោយអត្ថន័យពេញលេញ ។

គោលការណ៍ជាមូលដ្ឋាននៃសិទ្ធិមនុស្សនោះ គឺមនុស្សគ្រប់រូបមានសិទ្ធិ និងសេចក្តីថ្លៃថ្នូរស្មើៗគ្នា ដោយមិនគិតថា ជននោះជាអ្នកមាន ឬជាអ្នកក្រ ក្មេង ឬចាស់ ជាអ្នកទន់ខ្សោយ ឬមានអំណាចឡើយ ។ ទោះបីជាគោលការណ៍នេះធ្វើអោយមានការប៉ះពាល់ដល់របៀបរបបចាត់ចែងជាក់ស្តែងនៅក្នុងសង្គមមួយចំនួន ក៏ប៉ុន្តែវាបានបង្កើតឱ្យមានលទ្ធភាពក្នុងការប្រាស្រ័យទាក់ទងគ្នាដោយផ្អែកលើការគោរពគ្នាទៅវិញទៅមក និង ភាពត្រឹមត្រូវ ។

សាមគ្គីភាព ដែលជាគោលការណ៍សំខាន់មួយទៀតនៃសិទ្ធិមនុស្ស ទទួលស្គាល់ថា យើងទាំងអស់គ្នាគឺជាមនុស្ស យើងមានសេចក្តីត្រូវការ និងបំណងប្រាថ្នាដូចៗគ្នា ។ ដូច្នោះហើយ យើងមិនអាចសំរេចបំណងប្រាថ្នាទាំងនេះបានឡើយ ប្រសិនបើអ្នកដទៃទទួលរងនូវការធ្វើអាជីវកម្ម និងការសង្កត់សង្កិន ហើយដែលការឈឺចាប់ និងការប្រមាថមើលងាយទៅលើអ្នកដទៃ នឹងអាចកើតមានមកលើខ្លួនឯងវិញជាមិនខាន ។ សិទ្ធិ មានន័យថា យើងទាំងអស់គ្នាត្រូវប្រព្រឹត្តទៅលើមនុស្សដែលនៅជុំវិញខ្លួនយើង ដោយការអត់ឱន ការគោរព និងការយោគយល់គ្នា ។ តាមរយៈសិទ្ធិក្នុងការសំដែងមតិ និងសិទ្ធិក្នុងការបង្កើតសមាគម យើងទាំងអស់គ្នាអាចពិភាក្សាផ្លាស់ប្តូរមតិយោបល់ដោយសន្តិវិធី និងដោយសហការគ្នា នៅក្នុងសហគមន៍យើង ។ សិទ្ធិមនុស្សក៏មានន័យសំដៅទៅលើការទទួលខុសត្រូវរបស់យើង ចំពោះអ្នកជិតខាង និងចំពោះសង្គម របស់យើងផងដែរ ។

សិទ្ធិការពារយើង ពីភាពអយុត្តិធម៌ ឬការគ្រប់គ្រងដោយសង្កត់សង្កិន សិទ្ធិបង្កើតនូវវិធានខាងទំនាក់ទំនងរវាងប្រជាពលរដ្ឋនិងរដ្ឋ ។ សិទ្ធិអាចឱ្យប្រជាពលរដ្ឋជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន និងកំណត់អំពីគោលនយោបាយរដ្ឋ ។ សិទ្ធិសំដៅដល់ការចូលរួម និងការពិភាក្សាផ្លាស់ប្តូរមតិយោបល់ ។ សិទ្ធិធានាអំពីការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងសេចក្តីសុចរិតនៃអ្នកដឹកនាំរបស់ខ្លួន ។

មនោគតិនៃសេចក្តីថ្លៃថ្នូរ ដែលជាស្នូលនៃសិទ្ធិទាំងអស់ មានន័យថា សង្គមត្រូវខិតខំធានាឱ្យមនុស្សគ្រប់រូបមានសន្តិសុខ និងបំពេញបានរាល់សេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្ស ដូចជា ម្ហូបអាហារ ជំរក សំលៀកបំពាក់ និងទឹកស្អាត ជាដើម ។ ប្រសិនបើគ្មានលក្ខខណ្ឌទាំងនេះទេ មនុស្សគ្រប់រូបមិនអាចចូលរួមក្នុងសកម្មភាពសង្គមដោយស្មើភាពគ្នាបានឡើយ ។

កុមារ និងយុវជនកម្ពុជា តំណាងអោយសេចក្តីសង្ឃឹមសំរាប់អនាគតនៃប្រទេសកម្ពុជា ហើយក្នុងន័យនេះ គោលការណ៍ទាំងឡាយ ដែលខ្ញុំបានគូសបញ្ជាក់ដោយសង្ខេបនៅទីនេះ អាចក្លាយទៅជាការពិតជាក់ស្តែង ។ នៅក្នុងឱកាសទិវាសិទ្ធិមនុស្សនេះ ខ្ញុំសង្ឃឹមថា កុមារ យុវជន និងមាតា បិតា គ្រប់រូបអាចពិភាក្សាគ្នា អំពីអត្ថន័យពិតប្រាកដនៃសិទ្ធិមនុស្ស ដើម្បីដោះស្រាយបញ្ហាជាច្រើនរបស់ប្រទេសជាតិ ។ ការពិភាក្សានេះ អាចផ្តើមធ្វើនៅតាមក្រុមគ្រួសារនីមួយៗ បុគ្គលគ្រប់រូប នៅតាមសាលារៀន នៅតាមដងផ្លូវ និងនៅទីផ្សារ ក៏ដូចជានៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃក្នុងសង្គមកម្ពុជាផងដែរ ។

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១០ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧